00687303

E87

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-អជសដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ស្ថានភាពចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ លោក អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទៅលើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងនៅឯកិច្ចប្រជុំរៀបចំសវនាការ**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវី:** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម **និល ណុន** ជាប្រធាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម **ឌូ មណី** | លោក Andrew CAYLEY |
| | ចៅក្រម **យ៉ា សុខន** | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបម្រុង **យូរ ឧត្តរា** | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបម្រុង Claudia FENZ | |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 11 / 05 / 2011
ម៉ោង (Time/Heure) : 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្ដី") សូមស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តាចេញសេចក្ដីសម្រេចជាបន្ទាន់មួយទាក់ទិននឹងបញ្ហាជាក់លាក់នានា ដែលបានលើកឡើងនៅឯកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១។ ជាពិសេស មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តាចេញសេចក្ដីសម្រេចមួយ ទាក់ទិននឹងរយៈពេលរបស់ភាគីនីមួយៗសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបើក និងថាតើភាគីអាចជួបជាមួយសាក្សីដែលបានស្នើឡើង និងសាក្សីជំនាញ បាន ឬមិនបាន។

## I. ប្រវត្តិ

១. នៅឯកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីការពារក្ដី លោក **នួន ឌា** បានលើកឡើងនូវបញ្ហាទាក់ទិននឹងរយៈពេលសម្រាប់ការធ្វើសេចក្ដីសន្និដ្ឋានបើក ដូចមានចែងក្នុងវិធាន៨៨ *ស្ទួន* ថា៖

> ខ្ញុំចង់មានចំណុចតូចមួយចង់លើកឡើងផងដែរ។ គឺការបញ្ជាក់ពន្យល់ទៅលើវិធាន៨៩ស្ទួន វាក្យខណ្ឌទី២ ខ្ញុំដឹងថា យើងមិនទាន់ដល់សវនាការអង្គសេចក្ដីទេ ប៉ុន្តែយ៉ាងណាក៏ដោយ ដើម្បីការរៀបចំ យើងខ្ញុំចង់ទទួលការណែនាំលើពាក្យថា "សារណា" ដែលមានចែងនៅក្នុងអនុវិធាន២ នៃវិធាន៨៩ស្ទួន។ បទប្បញ្ញត្តិនេះចែងថា "មុនពេលដែលសួរទៅកាន់ជនជាប់ចោទ សហព្រះរាជអាជ្ញាត្រូវធ្វើសេចក្ដីសន្និដ្ឋានបើកដោយសង្ខេបចោទប្រកាន់ទៅលើជនជាប់ចោទ ហើយបន្ទាប់មកជនជាប់ចោទ និងមេធាវីត្រូវការឆ្លើយតបដោយសង្ខេប"។ ដូច្នេះ ខ្ញុំឆ្ងល់ថា តើអង្គជំនុំជម្រះបានពិចារណាយ៉ាងម៉េចដែរ ទៅលើពាក្យថា "សង្ខេប ដោយសង្ខេប" នេះ? យើងចាប់ផ្ដើម ដើម្បីឲ្យយើងអាចចាប់ផ្ដើមរៀបចំការឆ្លើយតបរបស់យើងទៅវិញ ថាតើសារណាសេចក្ដីសន្និដ្ឋានបើកនោះវាយ៉ាងម៉េច? ហើយធ្វើឡើងដោយសង្ខេបនោះគឺយ៉ាងម៉េចដែរ?[១]

២. មេធាវីការពារក្ដី លោក **នួន ឌា** ក៏បានលើកឡើងនូវបញ្ហាថាតើភាគីអាចទាក់ទងជាមួយសាក្សីដែលបានស្នើឡើងថា៖

---

[១] ប្រតិចារឹក ឯកសារលេខ E1/2.1 ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ៩៤-៩៥ (ភាសាខ្មែរ)។

ខ្ញុំក៏ចង់ទទួលបានការណែនាំពាក់ព័ន្ធទៅនឹងបញ្ហាសាក្សីផងដែរ ដូចដែលលោក លោកស្រីជ្រាបហើយ ក្នុងពេលដែលយើងចាប់ផ្ដើមកិច្ចស៊ើបសួរ យើងបានទទួលលិខិតសេចក្ដីសម្រេចពីខាង អូ ស៊ី អាយ ជេ មួយច្បាប់ ដែលបង្គាប់ឱ្យយើងកុំឱ្យពាក់ព័ន្ធទាក់ទងជាមួយនឹងសាក្សី ហើយមិនឱ្យយើងធ្វើការស៊ើបអង្កេតណាមួយក្នុងនាមមេធាវីការពារក្ដី។ ដូច្នេះ ខ្ញុំចង់ចោទសួរថា តើៗអ៊ីចឹងទៀតដែរឬទេយើងនៅតែមិនអាចនិយាយទាក់ទងជាមួយនឹងសាក្សីដដែល ឬក៏យ៉ាងម៉េច? តើយើងនៅតែទទួលការហាមឃាត់មិនឱ្យមានការស៊ើបអង្កេតដដែល មុនពេលចាប់ផ្ដើមនៃសវនាការឬក៏យ៉ាងណា? គឺមិនយើងមិនអាចទាក់ទងធ្វើការស៊ើបអង្កេត ឬក៏ទាក់ទងជាមួយនឹងសាក្សីមុនពេលដែលសវនាការចាប់ផ្ដើម ឬក៏យ៉ាងណា?[២]

៣. បញ្ហាទាក់ទងជាមួយសាក្សីដែលបានស្នើឡើងជាបញ្ហាមួយដែលធ្លាប់បានកើតឡើងពីមុន តែបញ្ហាថាតើការជួបជាមួយសាក្សី ឬពីវិសាលភាពដែលអាចទាក់ទងជាមួយសាក្សី ឬសាក្សីដែលបានស្នើឡើងដោយរបៀបណានោះ មិនទាន់បានដោះស្រាយសម្រាប់ដំណាក់កាលសវនាការនៅឡើយទេ នៅក្នុងកិច្ចដំណើរការនីតិវិធីមុនសវនាការអង្គសេចក្ដី ក្រុមមេធាវីការពារក្ដីទាំងអស់ត្រូវបានហាមឃាត់មិនឱ្យទាក់ទងជាមួយសាក្សីសំខាន់ៗទេ[៣]។ នៅដំណាក់កាលសវនាការអង្គសេចក្ដី មេធាវីការពារក្ដី លោក **នួន ជា** ស្នើសុំអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យភាគីអាចធ្វើការទាក់ទងជាមួយសាក្សីបានផង[៤]។ មកដល់ពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញសេចក្ដីណែនាំលើបញ្ហានេះនៅឡើយទេ។

---

[២] *ដូចជើងទំព័រខាងលើ* ទំព័រ៩៤ (ភាសាខ្មែរ)។

[៣] *សូមមើលជាឧទាហរណ៍* ការឆ្លើយតបរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៧ ស្ដីពីការស៊ើបអង្កេត ឯកសារលេខ A110/I ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ ទំព័រ២, ដីកាសម្រេចធ្វើការព្រមាន ដោយអនុលោមតាមវិធាន៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារលេខ D367 កថាខណ្ឌ៩។

[៤] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានស្នើឡើង ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/4/4 កថាខណ្ឌ១៣៖ "ក.ស.ព បានបញ្ជាក់ថា "សហព្រះរាជអាជ្ញាមិនទាន់បានទាក់ទងជាមួយអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីទេ"។ ទាក់ទងនឹងការហាមឃាត់ជាទូទៅប្រឆាំងនឹងការសួរសាក្សីដោយផ្ទាល់ ក្នុងដំណើរការនីតិវិធីក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងបទបញ្ញា/ច្បាប់កម្ពុជាទាក់ទងនឹងបញ្ហានេះ ក្រុមមេធាវីការពារក្ដីសូមស្នើអង្គជំនុំជម្រះសាលាដំបូង ធ្វើ

## II. ឧឡឹករណ៍

៤. សេចក្តីសម្រេចទៅលើរយៈពេលនៃការធ្វើសេចក្តីសន្និដ្ឋានបើក និងបញ្ហាថាតើភាគីអាចទាក់ទងជាមួយសាក្សីដែលបានស្នើឡើង រួមទាំងអ្នកជំនាញផងនោះ នឹងជួយយ៉ាងច្រើនដល់ភាគីក្នុងការរៀបចំខ្លួនសម្រាប់សវនាការអង្គសេចក្តី។ នៅក្នុងសំណុំរឿង០០១ ក.ស.ព មានរយៈពេលពីរម៉ោងសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបើក[៥]។ មេធាវីការពារក្តី *ឌុច* ក៏ទទួលបានរយៈពេលស្មើគ្នាដែរ[៦]។ មេធាវីការពារក្តីស្នើថា ជនជាប់ចោទម្នាក់ៗគួរទទួលបានរយៈពេលស្មើគ្នានឹងពេលវេលាដែល ក.ស.ព ទទួលបានដែរ។ មេធាវីការពារក្តីស្នើថា រយៈពេល ១០ ម៉ោង ជារយៈពេលមួយដែលសមរម្យ។ មេធាវីការពារក្តីរៀបចំដាក់សារណាបន្ថែមទៀត ដើម្បីគាំទ្រដល់សំណើនេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សារណាទាំងនោះអាចជាជំនួយក្នុងការចេញសេចក្តីសម្រេច។

៥. ពាក់ព័ន្ធនឹងការទាក់ទងជាមួយសាក្សីដែលភាគីបានស្នើឡើងវិញ ប្រសិនបើភាគីទទួលដំណឹងអំពីការសម្រេចថាតើគួរអនុញ្ញាតឱ្យមានការទាក់ទងនោះ បានកាន់តែឆាប់ វាកាន់តែប្រសើរ ដើម្បីអាចឱ្យភាគីមានពេលវេលាសមស្របដែលនៅសេសសល់ ក្នុងការរៀបចំខ្លួនសម្រាប់សវនាការអង្គសេចក្តី។ ប្រការដែលសំខាន់ជាងគេបំផុតនោះគឺថា នេះជាចំណុចសំខាន់ដែលភាគីទាំងអស់ត្រូវតែមានការយល់ដឹងដូចគ្នាចំពោះសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទាក់ទិននឹងបញ្ហានេះ។ មេធាវីការពារក្តីស្នើសុំថា ភាគី*គួរ*ត្រូវបានអនុញ្ញាតឱ្យទាក់ទងជាមួយសាក្សី ដោយសារការទាក់ទងនេះនឹង៖ ១.ជួយធានាពីសមភាពនៃមធ្យោបាយក្នុងការតតាំងក្តី ដោយសារថា ក.ស.ព

---

ការរំពឹកដល់ ក.ស.ព និងក្រុមមេធាវីរបស់ភាគីដទៃ ឱ្យបន្តកាតព្វកិច្ចរបស់ពួកគេដោយជៀសវាងធ្វើទំនាក់ទំនងច្រើនជាមួយសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលមួយមុនពេលផ្តល់សក្ខីកម្ម"។

[៥] *សំណុំរឿង កាំង ហ្កេកអ៊ាវ* លេខ ០០១/១៨-០៧-១០០៧-អវតក-អជសង ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ E1/6.1 ទំព័រ១៖ "អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាអាចឡើងធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទបាននាពេលនេះ ដោយអនុលោមតាមវិធាន៨៩ស្ទួន(២)។ បើសហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់អង្គជំនុំជម្រះកំណត់មានរយៈពេល២ម៉ោង សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានអំពីបទចោទប្រកាន់នេះ។ សូមអញ្ជើញសហព្រះរាជអាជ្ញា"។

[៦] អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យ ឌុច ឡើងនិយាយ បន្ទាប់មកគឺក្រុមមេធាវីការពារក្តីរបស់គាត់។ មិនមានការបញ្ជាក់ថាអង្គជំនុំជម្រះនេះមានកម្រិតរយៈពេលជាក់លាក់រយៈពេលសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបើកនេះទេ តែរយៈពេលនេះស្មើនឹងរយៈពេលដែលផ្តល់ឱ្យសហព្រះរាជអាជ្ញាដែរ។

ត្រូវបានអនុញ្ញាតឱ្យជួបជាមួយសាក្សីសំខាន់ៗ ក្នុងដំណាក់កាលបើកកិច្ចស៊ើបសួរបឋម មុននឹងបញ្ជូនសំណុំរឿងទៅ ក.ស.ច.ស និង ២. អនុញ្ញាតឱ្យមេធាវីការពារក្តីអាចផ្តោតលើការរៀបចំសំណួរសម្រាប់សួរសាក្សីនៅក្នុងសវនាការអង្គសេចក្តី ដែលនឹងជួយធានាបាននូវល្បឿន និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី។ មេធាវីការពារក្តីនឹងរៀបចំដាក់សារណាបន្ថែមទៀត ដើម្បីគាំទ្រសំណើសុំនេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សារណាទាំងនោះអាចជាជំនួយក្នុងការចេញសេចក្តីសម្រេច។

III. **សំណូមពរ**

**អាស្រ័យហេតុនេះ** ដោយយោងតាមសំអាងហេតុខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាចេញសេចក្តីសម្រេចជាបន្ទាន់មួយ៖

ក. ទាក់ទងនឹងរយៈពេលសម្រាប់ឱ្យភាគីនីមួយៗធ្វើសេចក្តីសន្និដ្ឋានបើក និង

ខ. ថាតើភាគីអាចជួបជាមួយសាក្សីដែលបានស្នើឡើង រួមទាំងសាក្សីជំនាញផង បានឬមិនបាន។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដោយក្តីគោរព។

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១